**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៧៩. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១. នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១.នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២១ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន

- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-**

ត្រូវបានតម្លើងអត្រាអាករពិសេសពី ១០% ទៅ ២០% លើមុខទំនិញចំនួន ០២ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ៨៧០១.២០.១០ និង ៨៧០១.២០.៩០ ។

**មាត្រា ២.-**

ត្រូវបានកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញចំនួន ៦២ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន រួមមាន ៖

- តម្លើងអត្រាអាករនាំចេញពី ១០% ទៅ ១៥% លើមុខទំនិញចំនួន ៣៣ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ៤៤០៦.១០.០០ ៤៤០៦.៩០.០០ ៤៤០៧.១០.០០ ៤៤០៧.២១.០០ ៤៤០៧.២២.០០ ៤៤០៧.២៥.១០ ៤៤០៧.២៥.២០ ៤៤០៧.២៦.០០ ៤៤០៧.២៧.០០ ៤៤០៧.២៨.០០ ៤៤០៧.២៩.១១ ៤៤០៧.២៩.១៩ ៤៤០៧.២៩.២១ ៤៤០៧.២៩.២៩ ៤៤០៧.២៩.៣១ ៤៤០៧.២៩.៣៩ ៤៤០៧.២៩.៤១ ៤៤០៧.២៩.៤៩ ៤៤០៧.២៩.៥១ ៤៤០៧.២៩.៥៩ ៤៤០៧.២៩.៦១ ៤៤០៧.២៩.៦៩ ៤៤០៧.២៩.៧០ ៤៤០៧.២៩.៨០ ៤៤០៧.២៩.៩១ ៤៤០៧.២៩.៩២ ៤៤០៧.២៩.៩៩ ៤៤០៧.៩១.០០ ៤៤០៧.៩២.០០ ៤៤០៧.៩៣.០០ ៤៤០៧.៩៤.០០ ៤៤០៧.៩៥.០០ និងទីតាំងរងលេខ ៤៤០៧.៩៩.០០ ។
- តម្លើងអត្រាអាករនាំចេញពី ៥% ទៅ ១០% លើមុខទំនិញចំនួន ០៣ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ៤៤០៩.១០.០០ ៤៤០៩.២១.០០ និងទីតាំងរងលេខ ៤៤០៩.២៩.០០ ។
- តម្លើងអត្រាអាករនាំចេញពី ០% ទៅ ៥% លើមុខទំនិញចំនួន ១៨ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ៤៤១០.១១.០០ ៤៤១០.១២.០០ ៤៤១០.១៩.០០ ៤៤១០.៩០.០០ ៤៤១១.១២.០០ ៤៤១១.១៣.០០ ៤៤១១.១៤.០០ ៤៤១១.៩២.០០ ៤៤១១.៩៣.០០ ៤៤១១.៩៤.០០ ៤៤១២.១០.០០

៤៤១២.៣១.០០ ៤៤១២.៣២.០០ ៤៤១២.៣៩.០០ ៤៤១២.៩៤.០០
៤៤១២.៩៩.០០ ៤៤១៣.០០.០០ និងទីតាំងរងលេខ ៤៤១៤.០០.០០ ។

តម្លើងអត្រាអាករនាំចេញពី ០% ទៅ ១០% លើមុខទំនិញចំនួន ០៨ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៧០៩.០០.៩០ ២៧១៣.១១.០០ ២៧១៣.១២.០០
២៧១៣.២០.០០ ២៧១៣.៩០.០០ ២៧១៤.១០.០០ ២៧១៤.៩០.០០
២៧១៥.០០.០០ ៦៨០១.០០.០០ ៦៨០២.១០.០០ ៦៨០២.២១.០០
៦៨០២.២៣.០០ ៦៨០២.២៩.០០ និងទីតាំងរងលេខ ៦៨០៣.០០.០០ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១២ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ចម្លងជូន៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់សាលាខេត្ត និងសាលារាជធានី
- ដូចមាត្រា ៤
- រាជកិច្ច